Reçu le 28-8-50

INDOCHINE FRANÇAISE
RÉGIE
DU
DÉPÔT LÉGAL

# ចំណារណាក

ទស្សនាវដ្តីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

## លេខពិសេស ឆ្នាំថ្មី

Avril

ឆ្នាំទី ១ មេសា លេខ ៤

ព. ស. ២៤៩២ — ត. ស. ១៩៤៩

ទស្សនាវដ្តីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម - ក្រសែម

សំណាក់ការ លេខ ៣៩ អា., វិថីទុកញ្ជាំពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| | | ទំព័រ |
|---|---|---|
| ឥរដ្ឋាំខាល | សមាគមម៉ត្តសាលាជាលី | ១៤១ |
| វិចារណកថា | | ១២២ |
| ពិធីបូលដ្ឋាំ | ឈឹម - ក្រសែម | ១២៥ |
| សេចក្តីពិចារណាអំពីបូលដ្ឋាំ | ភិក្ខុ ប៉ាង - ខាត់ | ១៣៥ |
| សេចក្តីសង្ឃឹម | ហេង - យ៉ាន់ | ១៤៣ |
| ឧបត្ថម្ភដ្ឋាំថ្មី | ញូង - សើរ៉ង | ១៤៩ |
| ចំរៀងបូលដ្ឋាំ | ហេង - យ៉ាន់ | ១៥១ |
| បញ្ចូគន្ធៈ ( ឥមក ) សេចក្តីប្រែរបស់ភិក្ខុ | ប៉ាង - ខាត់ | ១៥៣ |



ជំនៃ្ជយរៀរ

- ១ ឆ្នាំ ..... ៤៦,០០
- ១ ឆមាស ..... ២៧, ០០
- ១ ត្រីមាស ..... ១៤, ០០
- ១ ក្បាល ..... ៥, ០០


អ្នកអានទាំងឡាយ៖ សូមអញ្ជើញបុះឈ្នោះជារ៉ៃ
ធំងបបួលញាតិមិត្តជួយជារ៉ៃ
ជីវិតទស្សនារដ្ឋសូមផ្ញើលើលោកអ្នក ។

# ពរជ្ជាំខាល

ស.ន.ក.ឧ.ដ្ឋ.ប្រជាជាធិបតេយ្យ
ម.ណ្ឌ.ភ.ព័ុទ្ធសាសនា
ឆ្នាះ.ភ្លឺ
ឆ្នាំ.ច.ស.ស័ក្តិ

ឆ្នាំឆ្លូវអស់កាល ដល់វេនឆ្នាំខាល ចូលគាំទ្រលោក

ទ្រព្យាធនប្រៃសើរ ដំណើរជ័យជោគ ទ្រអស់ទុរ្ភេត

ទុក្ខភ័យនានា ។ ឆ្នាំដែលទៅបាត់ លេបដីពជន្មសត្វ

ឥតគិតរួញរា អស់មួយឆ្នាំគត់ រលត់សព្វគ្រា

បើកទ្រព្យធរ យាយីគ្រប់ប្រាណ ។ គួរទ្រុសសង្វែគ

លែងនឹកតំរេក ទឹងគ្រឿងកំសាន្ត រិះរេរំពឹង

ផញ្ជឹងរកថាន រកទីកន្លែមក្សាន្ត ពឹងពាក់អាត្មា ។

គួរផ្ទាស់គំនិត ផ្ទាស់ការប្រព្រឹត្តិ ផ្ទាស់ទំងន៍ឥរិយា

តាមច្បាប់ពុទ្ធសាសន៍ ប្រសើរថ្លៃថ្លា កាយចិត្តវាចា

គ្រប់គ្រងព្យាបាល ។ ដោយតេជបារមី គុណរតនទំងន៍បី

សូមទ្រឆ្នាំខាល សម្បូណ៌ប្រុងប្រើង សាន្តគ្រាណាត្រកាល

សែនសុខវិសាល លើសឆ្នាំទំងន់ឡាយ ។ សូមខេត្តាប្តី

ចំរើនសិរី ស្ងប់ស្ងុះសាយ ទុក្ខសោកឥតមាស

វិនាសខ្ចាត់ខ្ចាយ រលត់អន្តរាយ ជានិរន្តរ៍អើយ!

សមាគមមិត្តសាលាបាលី

# វិចារណាកថា

យើងរមែងពឹងផ្អែកគ្នាទៅវិញទៅមកមានពុំបាន, ដែលពឹ
សេចក្តីត្រូវការធម្មតាសម្រាប់ទ្រទ្រង់ជីវភាព នៅមានសេចក្តីត្រូវការ
សំដែងចិត្តគំនិត ឬ សេចក្តីសុខទុក្ខរបស់ខ្លួន ប្រាប់គេឯងឲ្យបានដឹងឮ
ផង ឬឲ្យដួយពិចារណា ។ កិច្ចទាំងអស់នេះ នឹងសម្រេចបាន
ព្រោះអាស្រ័យវាចា គឺពាក្យសំដី ។ ប្រសិនបើ យើងកើតមកគ្មានវា
មានន័យយ៉ាងពុំចេញទាំងអស់គ្នា, ការរួមជីវិតជាមួយគ្នាក៏នឹងប្រព្រឹត្តទៅ
បានដោយលំបាកពន់ពេក ។ ហេតុនេះ, គប្បីបានវាបាទុកជាគុណ
សម្បត្តិវិសេសមួយ សម្រាប់មនុស្សជាតិ ព្រោះជាដំណួយញុំាងសង្គមឲ្យ
ដុះដាលបានដោយស្រួល ទាំងជាគុណជាតិអាចញុំាងសាមគ្គីធម៌នឹង
មេត្រីចិត្ត ឲ្យកើតបានដោយរឹតរាយក្នុងសង្គមនោះ ។ ។

វាចានេះ បើពោលដោយរួបរួម មានត្រឹម ២ យ៉ាង គឺ:

សុភាសិត "សំដីល្អ" ១, ទុព្ភាសិត "សំដីអាក្រក់" ១ ។

សំដីជាទុព្ភាសិត គឺពាក្យគំពេះគំរើយត្រគោះបោះបោកគ្រហឹកគ្រហឹក
ជាដើម គេរមែងស្អប់ខ្ពើមរអើម មិនចង់ឲ្យប៉ះពាល់ដល់ត្រចៀកទេ សូម្បី
មានអ្នកខ្លះទស្សាហ៍ប្រកែកដោយ ព្រោះជាពាក្យនាំឲ្យខាតប្រយោជន៍
នឹងសេចក្តីចំរើន ព្រមទាំងនាំឲ្យបែកសាមគ្គីរវាងមនុស្សជាតិ ។ កុំ
បាច់ពោលថ្វីដល់មនុស្ស សូម្បីតែសត្វតិរច្ឆាន ក៏មិនគាប់ចិត្តចំពោះវាចា

ជាទុព្ភាសិតដែរ ដូចគ្រឿងគោនន្ទវិសាលដែលមានដំណាលក្នុងគម្ពីរពុទ្ធ-
សាសនា ។ សំដីបែបនេះ ខុសទំនងនឹងបំណងនៃមនុស្សជាតិដូចបាន
ពោលមកហើយ ។

ចំណែកវាចាជាសុភាសិត គឺពាក្យល្អពីពេះទន់ភ្លន់សុភាពរាបសា
ជាសំដីច្បាសចាកគោស នាំឲ្យកើតប្រយោជន៍ធំសេចក្តីចំរើន ។ ក្នុង
សង្គមនីមួយ ៗ ប្រសិនបើ គេនិយមប្រើតែសំដីល្អ ការឈ្លោះទាស់ទែង
ខ្វែងគំនិតគ្នា មុខជានឹងរកទីផុតគោនគ្មានទេ ឯសេចក្តីសុខស្រុះស្រួល
ប្រុះសម្រួលគ្នា ដែលយើងគេរាល់គ្នាតែងត្រូវការនោះ នឹងហូរស្រោច
ស្រប់ត្រជាក់ត្រជុំយ៉ាងបរិបូណ៌ ហើយគេអាចសំឡឹងមើលមុខគ្នាបាន
ដោយមេត្រីចិត្តសព្វទិសទី ព្រោះហេតុនោះ វាចាសុភាសិតរមែងជាទី
ស្រឡាញ់ពេញចិត្តនៃមនុស្សទូទៅ ។

ក្នុងច្បាប់ពុទ្ធសាសនា លោកបានកំណត់ទុកថា វាចាសុភាសិត
ត្រូវប្រកបដោយអង្គ ៥ គឺ ១ – សំដីត្រូវតាមកាល ២ – សំដីទ្រឿង
៣ – សំដីទន់ភ្លន់ ៤ – សំដីមានប្រយោជន៍ ៥ – សំដីប្រកបដោយ
មេត្តាចិត្ត ។ សំដីបែបនេះឯងជាសំដីគួរប្រើ សមតាមទំនងនៃសេចក្តី
ត្រូវការរបស់មនុស្ស ។

ដូចេ្នះ វាចាជាគ្រឿងឧបត្ថម្ភមេត្រីភាពឲ្យលូតលាស់ទូលំទូលាយរវាង
មនុស្សជាតិ ទាំងជាគ្រឿងទំនុកបំរុងជីវិតរួមគ្នាក្នុងសង្គមឲ្យប្រព្រឹត្តទៅ

បាននោយស្រួល ។ ឯវាចាដែលសមរម្យដល់មនុស្សជាតិនោះ គឺវាចាសុភាសិត ជាសំដីដែលយើងអ្នកស្ងួនភ្ងាសុខត្រូវយកមកប្រើរៀងរាល់ថ្ងៃ ។ ដោយយល់យើញល្អមែបនោះ ទើបបុពណាចារ្យអប់រំកូននៅឲ្យថឹកកងវាចាសុភាសិត កុងគម្ពីរបុរាណ ដើម្បីឲ្យស័ក្តិនៅកងមាត់ ដោយការជួនពរសំណូសាធុការដល់គ្នាទៅវិញទៅមក តែបើបងឲ្យស័ក្តិនៅគ្រប់គ្រងរក្សារហូតទៅ យើងគប្បីប្តូរប្តាច់ប្រែតែវាចាខាងសុភាសិតជានិច្ច ។

វាចាជាសុភាសិត មានប្រយោជន៍សំខាន់សម្រាប់អ្នកប្រើ អាចបន្ធូរចិត្តរបស់យើងបានកុងពេលកំពុងខឹងនឹមនុស្សខ្លាំង ព្រោះបើយើងតាំងចិត្តមាំកុងពាក្យប្តូរប្តាច់ប្រែតែពាក្យជាសុភាសិតហើយ យើងគោងទប់ចិត្តរបស់យើងឲ្យស្ងប់ទៀតផង ដើម្បីបង្ក្រាបអាកប្បកិរិយាពៃរៃផ្សឹងដើម្បីស្ងួនបុកពាតរិយាបថឲ្យសមរម្យទៅតាមសណ្តាប់ធ្នាប់ជាមនុស្សថ្លៃថ្នូរ ។ មួយវិញទៀត វាចាសុភាសិត ជាកូនសោសម្រាប់បើកចិត្តបើកមេត្តាគប្រាណគ្រប់កន្លែង ជាហេតុនាំឲ្យដឹងគុណកុងគ្រួសារ កុងសង្គមកុងប្រទេស កុងលោក ឲ្យបានទទួលនូវសេចក្តីសុខស្រួល ជាគំរោះគាព ។

# តំណ ចូលឆ្នាំ

ទំនៀមចូលឆ្នាំរបស់ខ្មែរយើង ប្រព្រឹត្តតាមគតិ ២ យ៉ាង គឺ: ១- ចូលឆ្នាំតាមបន្ទូគតិ, ២- ចូលឆ្នាំតាមសុរិយគតិ ។

**បន្ទូគតិកាល** : ទំនៀមភាប់រឿងខែក្នុងបន្ទូគតិដូច្នេះ- ១ មិគសីរ ២ បុស្ស ។ ល ។ ១១ អស្សុជ ១២ កត្តិក ។ រួមគាំង ១២ ខែជា ១ឆ្នាំ គិតជាថ្ងៃមាន ៣៥៤ ថ្ងៃ តែបើឆ្នាំដែលមានអធិកមាស នឹងមាន ១៣ ខែ ។ ក្នុងខែនីមួយ ។ ចែកចេញជា ២ ប័ក្ខ គឺ សុក្កប័ក្ខ ( ខាងខ្នើត ) កាឡប័ក្ខ ( ខាងរនោច ) ។ តាមប្រវៃណី ឥណ្ឌូក្តី ខ្មែរក្តី អំពីដើមមកនិយមប្រើខាងរនោចជាដើមខែ តែកាលក្នុងដើមក ប្រកបតាមសេចក្តីកត់ហេតុរបស់បព្វជិតចិនឈ្មោះ ហ្សួនឆាង ដែលទៅស៊ើបព្រះពុទ្ធសាសនានៅឥណ្ឌូក្នុង ព. ស. ១.២០០ ថាឥណ្ឌូបានប្តូរប្រើខាងខ្នើតជាដើមខែហើយ ។ ចំណែកខាងខ្មែរយើង តាមសេចក្តីកត់ហេតុរបស់ភូតចិនឈ្មោះ ជាវគាកួន ដែលមកស្រុកយើងក្នុង ព. ស. ១២៩៥ នោះយើញថានៅប្រើខាងរនោចជាដើមខែនៅឡើយ, ប្រមាណមកដល់ ព. ស. ១.៨៩០ ទើបបានប្តូរជាក់ខ្នើតជាដើមខែដូចឥណ្ឌូ ។

**រដូវ ៣ ក្នុងបន្ទូគតិ**: ក្នុងមួយឆ្នាំ លោកចែកជា ៣ រដូវគឺ ១- ហេមន្ត: រដូវរងា, ២- គិម្ហ: រដូវក្តៅ, ៣- វស្សាន: រដូវភ្លៀង ។

កំណត់ខែតនៃរតូវទាំង ៣ តាមប្រវេណីដើមដែលរាប់រានោចជា-ដើមខែ:- ហេមន្ត: គិតពី ១ រោចខែមិគសីរ ដល់ ១៥ កើតខែផល្គុន រួម ៤ ខែ ។ គិម្ហ: គិតពីថ្ងៃ ១ រោចខែចេត្រដល់ ១៥ កើតខែអាសាធ រួម ៤ ខែ ។ វស្សាន: គិតពី ១ រោចខែស្រាពណ៍ដល់ ១៥ កើតខែកត្តិក រួម ៤ ខែ ។

កំណត់ខែតនៃរតូវ ៣ តាមប្រវេណីកឋិបច្ចុប្បន្ន:- ហេមន្ត: ពី ១ រោចខែកត្តិកដល់ ១៥ កើតខែផល្គុន ។ គិម្ហ: ពី ១ រោចខែផល្គុន ដល់ ១៥ កើតខែអាសាធ ។ វស្សាន: ពី ១ រោចខែអាសាធ ដល់ ១៥ កើតខែកត្តិក ។

ឬនខែកឋិនរតូវរងា ជាដើមឆ្នាំ, ឬនខែកឋិនរតូវក្តៅ ជាកណ្តាលឆ្នាំ, ឬនខែកឋិនរតូវក្រៀងជាចុងឆ្នាំ ។ ដោយហេតុរឿងរតូវដូច្នេះ ដើមឆ្នាំកឋិនបន្ទុគតិ នើបធ្លាក់នៅតែងំខែមិគសីរ គឺខែមិគសីរជាខែទី ១ ឬល ។ ខែកត្តិកជាខែទី ១២; លេខរឿងបែបនេះ នៅជាប់មកដល់សព្វថ្ងៃនេះ ។

ពុទ្ធបញ្ញត្តិទាំងឡាយដែលទាក់ទាមដោយបរិច្ឆេទកាល មានថ្ងៃ ១៤ ញឹក ទោសថជាដើម ស្មុនតែតម្រូវតាមបន្ទុគតិទាំងអស់ ។

**សរិយគតិកាល:** ខែកឋិនសរិយគតិមានចំនួន ១២ ស្មើគានឹងខែកឋិនបន្ទុគតិ ប្លែកតែឈ្មោះខែ នឹងចំនួនថ្ងៃ ។ តាមតម្រាដើមរបស់យើងពាក់រឿងដូច្នេះ

| | | | |
|---|---|---|---|
| ១ – មេសា | មាន ៣០ ថ្ងៃ | ៧ – តុលា | មាន ៣១ ថ្ងៃ |
| ២ – ឧសភា | – ៣១ – | ៨ – វិច្ឆិកា | – ៣០ – |
| ៣ – មិថុនា | – ៣០ – | ៩ – ធ្នូ | – ៣១ – |
| ៤ – កក្កដា | – ៣១ – | ១០ – មករា | – ៣១ – |
| ៥ – សីហា | – ៣១ – | ១១ – កុម្ភៈ | – ២៨ – (១) |
| ៦ – កញ្ញា | – ៣០ – | ១២ – មីនា | – ៣១ – |

បូកថ្ងៃក្នុងខែទាំង ១២ នេះ ត្រូវជា ៣៦៥ ថ្ងៃ ។

ការដែលរាប់ខែមេសាជាខែទី ១ ដោយកំណត់តាមលំដាប់រាសីដែលព្រះអាទិត្យគោចរ គឺក្នុងមួយ ។ ព្រះអាទិត្យចាប់គោចរចេញពីរាងមេសរាសីដែលជាបឋមរាសី រៀងទៅដល់ មីនរាសី ហើយចូលមកក្នុងរាងមេសរាសីវិញ ហៅថា ដុំពិភពម្ដងរាប់ជា ១ ឆ្នាំ ។

ចំណែកប្រទេសទាំងឡាយដែលប្រើសុរិយគតិសុទ្ធ ដូចយ៉ាងប្រទេសចាមជាដើម ក្នុងបច្ចុប្បន្ន ចាប់កំណត់យកខែយ៉ាងវិយរ (មេសរ) ជាខែទី ១ ។

មកដល់ឆ្នាំ គ. ស. ១៩៤៩ ខ្ញុំរយើងបានផ្លាស់ប្តូរប្រើថ្ងៃ-ខែតាមសុរិយគតិក្នុងផ្លូវការខ្លះដែរ តែប្រើអនុលោមទៅតាមអឺរុប ដោយកំណត់យកខែមករាជាខែទី ១ ។

---

(១) ក្នុងឆ្នាំដែលលើកអធិកវារៈ មាន ២៩ ថ្ងៃ ។

កង់សុរិយគតិមិនទៀងមែ ក្បែរកង់ក្តី តារាក្តី, ដូចេះវិធីកត់ថ្ងៃខែ
តែវកត់ជាបួរណាស់ទៀ តឹកត់ថា: ថ្ងៃទី ១ ខែ..., ថ្ងៃទី ២ ខែ.. ។ល។
មិនកត់ថា ១ កើត ២ កើត ។ល។ ១ រោច ២ រោច ។ល។ ដូចកង់ចន្ទ
គតិដែ ។

## រឿង ៤ ក្នុងសុរិយគតិ: តាមសុរិយគតិកង់ ១ ឆ្នាំចែកចេញជា ៤

រឿងដូចេះ: —

១ — សិសិរ: រដូវរងា ៣ — វស្សាន: រដូវភ្លៀង

២ — ធិតាយ: រដូវក្តៅ ៤ — សរទ: រដូវប៉ុះអ័ព្ទ ។

កំណត់ខែនៃរដូវទាំង ៤ នេះដូចេះ = សិសិរ: ចេមាណពីពាក់
កណ្តាលវិច្ឆិកា ដល់ពាក់កណ្តាលកុម្ភ: ។ ធិតាយ: ចេមាណពីពាក់
កណ្តាលកុម្ភ: ដល់ពាក់កណ្តាលមិថុនា ។ វស្សាន: ចេមាណពីពាក់
កណ្តាលមិថុនា ដល់ពាក់កណ្តាលកញ្ញា ។ សរទ: ចេមាណពីពាក់
កណ្តាលកញ្ញា ដល់ពាក់កណ្តាលវិច្ឆិកា ។

ទំនៀមអារម្មកង់ចច្ចុប្បន្ន ចែកខែនៃរដូវ ៤ នេះ ឲ្យសន្ធឹងចែចាង
លើដូចេះ: —

១ — ចេរ៉ងតង់ប្រ៉ (ធិតាយ:) ពី ២១ ម៉ាស្រូដល់ ២១ យូភ្ញុំង ។
២ — អោតេ (វស្សាន:) ពី ២២ យូភ្ញុំង ដល់ ២២ សេបតមចែ ។
៣ — អូតូន (សរទ:) ពី ២៣ សេបតមចែដល់ ២១ ដេសមចែ ។

៤ – ហ៊ីវែរ (សិសិរ:) ពី ២២ ដេសមប្រែដល់ ២០ មា៉្យ ។ របៀបរៀងតូវតាមតម្រាបស់យើងខាំងក្នុងបន្ទូគតិ ខាំងក្នុងសុរិយគតិ សុទ្ធតែកំណត់យកតូវជាតូវទី ១ ចំណែកខាងអ៊ីរុបកំណត់យកតូវក្តៅជាតូវទី ១ ។

## ពិធីបួលឆ្នាំតាមបន្ទូគតិ

ពិធីបួលឆ្នាំជាពិធី ១ យ៉ាងដែលរាប់រួមក្នុងពិធីទ្វាទសមាស ទំនៀមខ្មែរយើងតាំងអំពីដើមរៀងមក ដល់ប្រមាណ ព. ស. ១៨៥០ ធ្លាប់បួលឆ្នាំតាមបន្ទូគតិ ដោយកំណត់យកតូវជាដើមឆ្នាំដូចពោល ហើយ សមដូចសេចក្តីកត់ហេតុបស់ជាវគាកូនដែលមកស្រុកខ្មែរក្នុង ព. ស. ១២៨៥ នោះថាខ្មែរបួលឆ្នាំតូវតែជាទី ១០ របស់ប៉ិន[1] គឺបួលតែរាងជាប់ខែកត្តិកនឹងខែមិគសីរ ដោយហេតុនេះ ទើបលោករៀងខែមិគសិរជាខែទី ១ ។

ពិធីនេះ មានកិច្ចធាក់ទាមដោយការបូជាចំពោះព្រះបន្ទូ ដោយហេតុនេះ ពិធីនេះទើបមានឈ្មោះថា «បន្ទាយណា:» តូវនឹងសំដីសាមញ្ញ ថាពិធីសំពះព្រះខែ ។

**របៀបរាង**:ពិធីនេះតូវធ្វើ ៣ ថ្ងៃតាមទំនៀមគឺថ្ងៃ ១៣·១៤ និង ១៥ កើតខែកត្តិក ។ **រណ្តាប់ប្បជា**: គ្រឿងបូជាតាមទំនៀមបូរាណយ៉ាងណា

---

១ ចំនួនប៉ាមេរយជាខែទី ៩, ខែទី ១ របស់ប៉ិនតូវលើខែកត្តិករៀងខ្មែរ ។

មិនអាចដឹងបាននោះទេ តែតាមផ្លូវគេរាប់ឃើញថាមិនប្លែកអំពី
របៀបដែលធ្វើក្នុងឆមាសប្បុន្តាន គឺវេលាយប់នាថ្ងៃ ១៣ - ១៤ កើត គេ
លើកគ្រឿងសក្ការៈមាន ឆ្លុះ ទៀន ប្រទីប ក្ដារ ជាដើមទៀបបូជា ។
ដល់យប់នៃថ្ងៃ ១៥ កើតជាពេលប្រជុំធំ គេតែងនាំគ្នាទៅប្រជុំនៅទីណា
មួយមានវត្តជាដើមហើយបូជា ។ ក្នុងពេលនេះមានបន្ថែមគ្រឿងបូជា
ច្រើន គ្រឿងបូជាទាំងនោះច្រើនតែរបស់ដែលជាពូជធារ មាន សណ្តែក
ល្ង ស្រូវ អង្ករ គ្រាវ ដំឡូង ដូង ស្លា អំពៅ ចេក អំបុក ជាដើមតាម
ដែលមាន, នឹងមានប្រាក់កាសបន្តិចបន្តួចផង ។

ក្នុងពេលដែលព្រះចន្ទ្រដើរត្រង់ពីលើក្បាល (ម៉ោង ១២ អធ្រាត)
គេក៏ផ្តើមធ្វើពិធីបូជា ។ ការដែលបូជាដោយរបស់ជាពូជធារដូច្នេះ ដោយ
មានគតិប្រកាន់ថា ព្រះចន្ទ្រជាទេវតាចំពូកជាតុទឹក ១ អង្គ, គេបូជាដោយ
របស់យ៉ាងនេះ ដើម្បីសូមឲ្យក្ងៀងធ្លាក់ត្រូវតាមរដូវកាល នឹងសូមឲ្យរប
ស់ផ្លែកសិកម្មបានផលបរិបូណ៌ ។ កាលបូជារួចហើយ គេក៏យករបស់
ទាំងនោះ ដាក់នៅផែដើមចេកបណ្តែតទឹកទៅ ។ រាប់ថា ចប់កិច្ចបូជា
ព្រះចន្ទ្រដោយសង្ខេបប៉ុណ្ណោះ ។

## ពិធីបួលឆ្នាំតាមសុរិយគតិ

ពេលបួលឆ្នាំតាមសុរិយគតិតាមតម្រាហោរាហៅ «អាយន្តុសង្ក្រាន្ត»
ទោះលោកវៀងរដូវធ្លាប់ជារដូវទី ១ តែពេលបួលឆ្នាំតាមសុរិយគតិមិនបាន

តម្រូវតាមលំដាប់ត្រូវទេ កំណត់យកត្រង់ពេលព្រះអាទិត្យដើរត្រង់ពីលើ
ក្បាល គឺត្រូវត្រង់ថ្ងៃទី ១៩ ខែមេសា ។ ការបូលឆ្នាំតាមសុរិយគតិ
គឺជាការបូជាចំពោះព្រះអាទិត្យ ដោយហេតុនេះ ពិធីនេះទើបមានឈ្មោះ
ថា «អាទិត្យាយណៈ» ព្រៃថាពិធីដែលទាក់ទងដោយព្រះអាទិត្យ ។
សេចក្តីពិត ខ្មែរយើងអំពីដើមរៀងមកធ្លាប់បូលឆ្នាំតាមចន្ទគតិដូចពោល
ហើយ ទើបតែនឹងមកផ្លាស់បូលឆ្នាំតាមសុរិយគតិប្រមាណក្នុង ព. ស.
១៨៩០ ទោះបីផ្លាស់មកដូច្នេះក្តី វិធីប្រែថ្ងៃ - ខែ - បក្ខ នឹងត្រូវនៅ
និយមតាមចន្ទគតិចាំងស្រឹង ។ លុះមកដល់ឆ្នាំ គ. ស. ១៩៤៨ ដែល
កើតរដ្ឋសភាហើយ ទើបបានប្រែ ថ្ងៃ - ខែតាមសុរិយគតិកងផ្លូវការ ។

**របៀបការ**: ពិធីនេះត្រូវធ្វើ ៣ ថ្ងៃតាមទំនៀម គឺថ្ងៃ ១៣ - ១៤
ទឹង ១៥ ខែមេសា ការធ្វើពិធីធំ ប្រហែលជាមានកំណត់ពេល បើគិត
តាមយាមដែលព្រះអាទិត្យរះ គួរធ្វើក្នុងវេលាថ្ងៃ គឺត្រង់ពេលថ្ងៃត្រង់ ។
បើគិតតាមតម្រាថាស់ ១ យ៉ាងដែលកំណត់ចែកថ្ងៃ ត្រូវធ្វើវេលាយប់ គឺ
ត្រង់ពេលអធ្រាត្រ ។

**រណ្តាប់ប្អូជា** គ្រឿងបូជាតាមទំនៀមបុរាណនោះយ៉ាងណាខ្លះ មិន
អាចដឹងបានដោយសព្វគ្រប់ តែគង់មិនដូចប្រពៃណីដែលធ្វើក្នុងបច្ចុប្បន្ន
តាមផ្លូវសន្និដ្ឋានថា គេគង់បូជាដោយគ្រឿងយជ្ញ មានបង់សាច់សត្វក្នុង
រណ្តៅភ្លើងជាដើម ដោយហេតុព្រះអាទិត្យជាទេវតាចំពូកជាតុភ្លើង សឹង

កំណត់ខែតនៃរតូវទាំង ៣ តាមបែរណីដើមដែលរាប់រនោចជា-
ដើមខែ:— ហេមន្ត: គិតពី ១ រោចខែមិគសីរ ដល់ ១៥ កើតខែផល្គុន
រួម ៤ ខែ ។ គិម្ហ: គិតពីថ្ងៃ ១ រោចខែចេត្រដល់ ១៥ កើតខែអាសាធ
រួម ៤ ខែ ។ វស្សាន: គិតពី ១ រោចខែស្រាពណ៍ដល់ ១៥ កើតខែកត្តិក
រួម ៤ ខែ ។

កំណត់ខែតនៃរតូវ ៣ តាមបែរណីកឯបច្ចុប្បន្ន:— ហេមន្ត: ពី
១ រោចខែកត្តិកដល់ ១៥ កើតខែផល្គុន ។ គិម្ហ: ពី ១ រោចខែផល្គុន
ដល់ ១៥ កើតខែអាសាធ ។ វស្សាន: ពី ១ រោចខែអាសាធ ដល់
១៥ កើតខែកត្តិក ។

បួនខែកឯរតូវរដា ជាដើមឆ្នាំ, បួនខែកឯរតូវក្តៅ ជាកណ្តាលឆ្នាំ,
បួនខែកឯរតូវក្រៀងជាចុងឆ្នាំ ។ ដោយហេតុរៀងរតូវដូច្នេះ ដើមឆ្នាំកឯ
បន្ទូតិ៍ ទើបធ្លាក់នៅតែងខែមិគសីរ គឺខែមិគសីរជាខែទី ១ ឬល ។
ខែកត្តិកជាខែទី ១២; លេខរៀងបែបនេះ នៅជាប់មកដល់សព្វថ្ងៃនេះ ។
ពុទ្ធបញ្ញត្តិទាំងឡាយដែលទាក់ទាមដោយបរិច្ឆេទកាល មានថ្ងៃ
ទុបោសថជាដើម ស្មុនតែតែមរតាមបន្ទូតិ៍ទាំងអស់ ។

**សុរិយគតិកាល:** ខែកឯសុរិយគតិមានចំនួន ១២ ស្មើគានឹងខែ
កឯបន្ទូតិ៍ ប្លែកតែឈ្មោះខែ និងចំនួនថ្ងៃ ។ តាមតែមាដើមរបស់យើង
ពាប់រៀងដូច្នេះ

គ) – រឿងសង្ឃានុស្សតជារឿងទើបកើតមានឡើងក្នុងសម័យនេះ តែជាគួរយកជាយុទ្ធសាស្ត្រសម្រាប់អ្នកការពារព្រះពុទ្ធសាសនា ។

**សរុបសេចក្តី** កិច្ចទាំងឡាយក្នុងពិភពលោកនេះ ទោះបីយ៉ាងណាក៏ដោយ គប្បីជាបថាជាកិច្ចប្រព្រឹត្តទៅតាមសេចក្តីនិយមប្លែកៗក្នុងគតិសាសនាក្នុងសម័យនោះៗប៉ុណ្ណោះ ។ ក្នុងសម័យនេះការដែលនឹងធ្វើឲ្យតឹមត្រូវសមរម្យតាមហានៈនៃយើងជាអ្នកការពារព្រះពុទ្ធសាសនា ហើយជាប្រយោជន៍ពិតប្រាកដផងនោះគប្បីជាបដូច្នេះ :

១ – **ជំរះបញ្ចរបរ** ក្នុងពេលដាច់ខាតសម្រាប់ពិចារណាមើលយើងត្រូវគិតគូរមើលកិច្ចការគ្រប់ចំពូកដែលយើងបានប្រកបមកហើយ ប៉ើយើញថាកិច្ចការណាបានចំរើនលូតលាស់ហើយ យើងត្រូវបំពេញកិច្ចការនោះឲ្យរឹងរឹតតែចំរើនឡើង ប៉ើយើញកិច្ចការណាទន់ខ្សោយ ត្រូវចាត់ចែងកិច្ចការនោះឲ្យបានចំរើនឡើង ។

**២ – ជំរះបិត្ត** យើងត្រូវពិនិត្យមើលទឹកចិត្តរបស់យើង ប៉ើយើញថាក្នុងរាងដែលកន្លងមកហើយ ចិត្តរបស់យើង ប្រព្រឹត្តទៅក្នុងផ្លូវសុប់តាមគន្លងធម៌ហើយក៏គប្បីផ្គត់ផ្គង់ចិត្តបែបនោះ ឲ្យរឹងរឹតតែចំរើនឡើងទៀត ប៉ើយើញថាចិត្តរបស់យើងទន់ខ្សោយប្រសើលាប់ទៅក្នុងផ្លូវអកុសល

ច្រើន គប្បីរៀបចំចង្ហាន់ជាច្រើន ឲ្យប្រគេនភ្លាមៗ ឲ្យបានមុតមាំ
ពេញលេញទើង ពោលដោយសង្ខេប គឺព្យាយាមលះអកុសលឲ្យអស់
ទៅ ព្យាយាមចំរើនកុសលឲ្យបរិបូណ៌ទើង ។

## ៣ - បរិច្ចាគ

ការដែលយើងខំធ្វើការកសាងក្នុងវេន ១ ឆ្នាំមក
នេះ យើងត្រូវបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានជាពិសេស គឺ :

ក)- អ្នកមានគុណ មានមាតាបិតាជាដើម យើងត្រូវតែផ្គត់ផ្គង់ជា
ដរាបមក តែក្នុងឧកាសបូលឆ្នាំនេះ យើងត្រូវតែបំពេញកិរណីយកិច្ច
នេះជាពិសេស ដោយការផ្គត់ផ្គង់រំកាយជូនអាហារបរិភោគជូនគ្រឿង
ប្រើប្រាស់មានសំពត់អាវនឹងប្រាក់កាសជាដើម ។

ខ)- ត្រូវបរិច្ចាគទានចំពោះព្រះសង្ឃសមណៈអ្នកប្រតិបត្តិធម៌នឹង
សង្ឃឹកព្រះសង្ឃ រហូតដល់ព្រះពុទ្ធរូប ក៏ប្រោសជំរុំសំអាតជាពិសេស ។
កិច្ចទាំងនេះជាដើម ជាកិរណីយកិច្ចដែលយើងអ្នកកាន់ព្រះពុទ្ធសាសនា
គប្បីធ្វើក្នុងឧកាសបូលឆ្នាំ ។

ចប់ពិធីបូលឆ្នាំដោយសង្ខេប

ឈឹម - គ្រែសម

# សេចក្តីពិចារណាអំពីចូលឆ្នាំ

នេះថ្ងៃចូលឆ្នាំ ។ ការងារទាំងអស់ត្រូវគេបញ្ឈប់មួយអន្ទឹសិន ។ វត្តអារាមនឹងគេហដ្ឋាន គេសំអាតតុបតែង រៀបគ្រឿងសក្ការបូជាទទួលទេវតាថ្មី ។ អ្នកស្រុក អ្នកនគរ ស្អិតស្អាងរូបរាងកាយប្រជាប់ដោយគ្រឿងអលង្ការដ៏វិចិត្រ មានមុខមាត់ញញឹមញញែញែមស្រស់បស់ សំដែងអាការឲ្យយើញច្បាស់ថា មានសេចក្តីរីករាយសប្បាយណាស់ ហាក់ដូចជារៀបខ្លួនទុកបំរុងចូលទៅកាន់ឋានសួគ៌ ។ សម្រាប់អ្នកឥតការពិចារណា មិនមានអ្វីប្លែកគ្រៅពីការប្រព្រឹត្តទៅតាមទម្លាប់ ធ្វើជាអ្នកស្ទាប់គំនិតសូន្យឈឹង ព្រមបណ្តោយខ្លួនស្រេលជាយទៅតាមពាក្យថាចូលឆ្នាំចុំបើកគុកាសឲ្យទំពាក្រឹ ស៊ីសាច់ឈាមបំបាត់ជីវិតពាំងស្រែ ។ សម្រាប់អ្នកសម្បុណិតការពិចារណា ការចូលឆ្នាំនេះ មិនមែនគ្រាន់តែជាការជាស់គ្រឿនស្មារតី ឲ្យភ្ញាក់រលឹកប៉ុណ្ណោះទេ ថែមទាំងនាំឲ្យកើតគំនិតជ្រាបទុកដូចជាប្រទីប អុជគ្រាលបំភ្លឺឲ្យយល់ច្បាស់នូវប្រស្នាក្នុងជីវិតយើងតាមយថាភូតទៀតផង ។

ការចូលឆ្នាំ ជាធម្មតាលោកនិយម គេកំណត់ធ្វើទៅតាមហោរាសាស្ត្រ គឺគេកំណត់យកវេរ:ថ្ងៃវែដែលប្រព្រឹត្តកន្លងទៅប៉ុណ្ណោះប៉ុណ្ណោះមកជាគោលទីតាំង សន្មតថា "ចូលឆ្នាំ" តែដល់ចក្រពស៍នោះវិលមកដល់កំណត់ហើយ គេត្រូវបចូលគ្នាចូលឆ្នាំ តាមដែលបានសន្មតទុក ។ ពាក្យថា ថ្ងៃ-វែ-ឆ្នាំ, សតវត្សរ៍, បុំលិង្គ, ឥត្ថីលិង្គ, នបុំសកលិង្គ, នេះកំសុទ្ធ

សឹងជាពាក្យសន្មត ហើយគេសន្មតអ្វីជាអ្វីតទៅទៀតមិនចេះចប់ ។ ការសន្មតនេះ លោកវាយថាជាសច្ចៈដែរ តែជាសម្មតិសច្ចៈ ។ លោកនេះពេញដោយពាក្យសន្មត ចិត្តយើងដែលជាប់ដោយៈលោកសន្មត រីលេទៅតាមលោកសន្មត ក៏ភ័ន្តវៃប្រទៅតាមលោកនិយមកើតជាខុបាទានប្រកាន់ថា ចូលឆ្នាំមែនទែន មិនតែប៉ុណ្ណោះទេ ថ្ងៃ - ខែ - ឆ្នាំ រហូតដល់រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ គប់រូបគប់នាមក៏ប្រកាន់ថា នេះរបស់អញ នោះជាអញ នុះជាខ្លួនអញ, អញទាំងអស់ដោះខ្លួនមិនរួចពីពាក្យសន្មតខ្លួនឯង, បងខ្លួនឯងដោយខ្យល់ គឺពាក្យសន្មត ហើយដោះមិនរួច, និមិត្តពាក្យខ្លួនឯងហើយស្រាយមិនរួច ។

មួយទៀត, ពាក្យថា "ចូលឆ្នាំ" តាមទំនងគង់ត្រូវមានពាក្យថា "ចេញឆ្នាំ" តែយើងមិនបានជាគិត, សូម្បីយើងធ្លាប់ចូលឆ្នាំមករាប់ ៥០ - ៦០ ឆ្នាំហើយ យើងក៏យកគំនិតទាំងដុលទៅគិតតែពីចូលឆ្នាំ ឥឡូវគិតតែពីសប្បាយ ។

"ចេញ ចូល" ជាពាក្យគូគ្នា ។ យើងសព្វថ្ងៃកំពុងរស់នឹងធម៌ជាគូ ជាប់ជំពាក់ចិត្តនឹងធម៌ជាគូ ដូចពាក្យថា រួច ជាប់ ស្វាប់ កើត ។ ល ។ តាមការពិចារណា ការចេញ ការចូល ការរួច ការជាប់ ការស្វាប់ ការកើត របស់យើងមិនមានសេចក្តីផ្សងទេ តែដោយយើងជាប់នៅក្នុងសំបកគឺអវិជ្ជា យើងក៏ត្រូវប់ជាយល់សេចក្តីខុសពីសេចក្តីពិតទៅវិញថា ការ

ចេញផ្សង់ ការចូលផ្សង់ ការរួចផ្សង់ ការជាប់ផ្សង់ ការស្អាប់ផ្សង់ ការកើតផ្សង់ ។ សេចក្តីពិត ពុំមែនដូចយើងយល់នោះទេ ការចេញគឺការចូលនោះឯង ការរួចគឺការជាប់នោះឯង ការស្អាប់គឺការកើតនោះឯង ។ ធម៌ណានៅមានជាប់ជាគូ ធម៌នោះពុំសមគួរនឹងកើតមានសេចក្តីសុខពិត ធម៌មិនមានគូ ទើបសមគួរជាធម៌ប្រកបដោយសេចក្តីសុខពិត ។ ការចេញស្រឡះ មិនមានការវិលទៅរកការចូលវិញ គឺការចេញមិនមែនការចូល ការចេញស្រឡះបែបចេញចាកសំសារវដ្ត, ការរួចស្រឡះ មិនមានការវិលទៅរកការជាប់វិញ គឺការរួចមិនមែនការជាប់ ការរួចស្រឡះបែបវិមុត្តិ, ការស្អាប់ មិនមានការវិលត្រឡប់មករកកើតវិញ គឺការស្អាប់មិនមែនការកើត ស្អាប់បែបអមតៈ បែបនិរោធៈ ឬ បែបនិព្វាន ។ ធម៌ពិតនេះមិនមានគូ មានតែមួយ ជាធម៌ឯក ឈ្មោះថា ឯកន្តបរមសុខ ។ ដូចេះលោកយើងនេះជាលោកពេញដោយធម៌ជាគូ យើងត្រូវចូលឆ្នាំហើយចេញឆ្នាំវិញ ចេញហើយយើងចូលវិញ ចេញចូលដដែលៗយ៉ាងនេះរហូតទៅមិនមានទីបំផុត ។

សេចក្តីដូចបានពណ៌នាមកនេះ យើញថាយើងសុខចិត្តបណ្តោយខ្លួនទៅតាមដំណើរ តតមាននរណាសើចនឹងនរណាទេ ព្រោះយើងមានរោគដូចគ្នា យើងនៅកងវដ្តវិលដូចគ្នា ។ តាំងនេះ មកពីបសាទយើងមានចក្ខុបសាទជាដើមមិនសុក្រឹត មិនអាចមើលអ្វីឲ្យឃើញច្បាស់លាស់

តាមយថាភូតបាន ។ ឯការបេះដឹងយើង និង បញ្ញាយើងសោតក៏ត្រូវបិទបាំងយ៉ុកនៅក្នុងពន្ធនាគារ ក្នុងឧបក្កិលេសទាំងឡាយមានពាក្យសន្មតនឹងពាក្យគួរជាដើមទៀត ។ ខ្លួនយើងមានទំនងដូចអ្នកដំណើរវែលត្រាច់រង្គាត់រាល់ខ្សាច់ដំណាត់ ហើយស្រែកទឹកខ្លាំងក្រៃឡែតយើញថ្ងៃបណ្តើរកូន នៅទីឆ្ងាយយោលត្រចៀមកមានអាការដូចរលកទឹក ក៏ស្មានថាជាទឹកមែន ខំប្រឹងធ្វើដំណើរស្រួតទៅតាន់ទីនោះ ដល់ហើយឥតយើញអ្វីសោះ យើញតែទេទេ ក៏ភ្លាត់ចាកសេចក្តីសង្ឃឹមអស់កម្លាំងកាយ កម្លាំងបិត្តឥតអំពើ ។

ឯរឿងនេះ រូបទំយមវិទ្យាក្នុងបច្ចុប្បន្នកាលបានត្រាលំភ្លឺឲ្យយើញជាក់ស្តែងហើយ ។ លោក រ៉ាំ - លិនសិន (Ram-Linssen) បានពន្យល់តាមការទិទ្ស្សន៍វិទ្យានេះយើញច្បាស់ហើយថាការសន្មតទុករូបធាតុជាសភាវៈ យន តាន់ នឹងភ្លល់ នឹងជាប់ជាដំណាតៗគ្នានោះមិនសមទៅតាមសេចក្តីពិតទេ ព្រោះអ្នកបានជ្រួបនិយមវិទ្យា បានសង្កេតមើលតាមពន្លឺកែវប្តូលទស្សន៍ទៅយើញថា លក្ខណៈទាំង ៤ យ៉ាងនេះ ពុំមានក្នុងតួរបធាតុឡើយ ។ មុខថ្មមួយដុំ ដែលយើងមើលដោយភ្នែកធម្មតា ភ្នែកមិនសុគ្រឹត យើញថារលឹងហ្មត់ល្អ តែឡប់ជាមានសភាពគ្រើមទៅវិញ បើពិនិត្យមើលទៅតាមកែវប្តូលទស្សន៍ ។ បើពង្រីកមកត្រង់ភម្ងាំងនុះឡើងខ្លាំងទៅទៀត យើងនឹងឃើញថា សាច់ថ្មមួយនោះធ្យែងដោយកំពេច

ធាតុស្ថិតតូច ។ ដាវែចនមិនប៉ះពាល់គ្នាយ៉ាងស្និទ្ធ ហើយកំរើកញាប់ញ័រ
រន្ធត់យ៉ាងរហ័សគួរសើច កំទេចធាតុស្ថិតនោះ គេហៅថា អណូ ។
អណូនេះ ធ្វើការកំរើកចំនួន ពប់ពាន់លានដងក្នុង ១ វិនាទី ដូចជាអណូ-
នៃពែង ដែលជាសញ្ញាលក្ខណៈនៃសភាវៈ យន តាន់ ទឹងថ្លល់
ទឹងជាប់ជាតំណាត ។ គ្នា អណូពែងនេះ ធ្វើការកំរើកចំនួន ១៩.០០០
បរគោដងក្នុង ១ វិនាទី ។ ឯអណូមានការផ្សំដោយកំទេចធាតុតូចផ្សេង
ទៀតលែងទៅទៀត ហៅថា បរមាណូ បើយកបរមាណូចំនួន ១០ គោដ
មកតំរៀបតគ្នាទឹងបានប្រវែងប៉ុនមួយមិល្លីម៉ែត្រប៉ុណ្ណោះ ។ ក្នុងរវាង
បរមាណូ មានបន្ទោះទំនេរគាគសំខាន់ប្រហែលទឹងបន្ទោះទំនេររវាងផ្កាយ
តាមដែលរកឮទំហំដើមទុក ។ អ្នកប្រាជ្ញបរទេសមានឈ្មោះ
ម្នាក់ឈ្មោះ ស៊ុលយូត - ដឺ កូរអ (Juliot de Curie) បានឲ្យទុទាហរណ៍
យ៉ាងដាក់ស្តែងថា បើគេយកបរមាណូដែលផ្សំអត្តភាពបុរសទម្ងន់ ៧០
គីឡូ មកគរលើគ្នាទឹងបានបរិមាត្រចំនួនប៉ុនធូលី ដែលយើងមើលឃើញ
តាមពន្លឺថ្ងៃក្នុងបន្ទប់ងងឹតនៃផ្ទះបង្អស់យើងនោះមួយគ្រាប់ប៉ុណ្ណោះ ។
ត្រង់ណាដែលយើងមើលទៅឃើញថា តាន់ ប្រែជាប្រហោង ទឹងថ្លល់
ប្រែទៅជាកំរើកទៅវិញ ម្ល៉ឺកំរេកទាំងអស់ កំលាំងអស់ ដូច្នេះហើយ
បានជាព្រះអង្គម្ចាស់ល្បីស័ដ្ឋប្រគ្លី (Louis de Broglie) សន្មតថាដែល
គេហៅថាសុទ្ធមរូបនោះ ជាកញ្ចប់នៃរលកធាតុ ជាទំបញ្ចុះពលភាព
ជាឋានផ្សាយឥន្ធិពល ដែលផ្ទាស់ប្តូរកន្លែងដោយល្បឿនមានកំណត់

ប្រកបដោយកំរាស់មានកំណត់ ។ ដូច្នេះយើងនឹងទុករូបធាតុ
ជាមានសភាវៈ យន តាន់ នឹងថ្កល់ ជាប់ជាតំណត។ គ្មានពុំបានទេ ។ ថ្វីម
ថ្មរលីងខាងក្រៅ ដែលយើងមើលទៅឃើញ យន នឹងថ្កល់នោះ គ្រាន់
តែជាមាយារូបដូចថ្មបាណ៏រកូន ។ រូបនិយមវិទ្យាសម័យថ្មីជាវិជ្ជាវិសេស
ខាងរូបធាតុ បានបកសោតរូបធាតុ បង្ហាញឲ្យយើញច្បាស់ហើយថាឥត
ខ្វីមសារឡើយ ។ រូបដែលយើងមើលទៅឃើញថា វ៉ែនឹងថ្កល់នោះ
មកតែពីចក្ខុបសាទយើងមិនសុគ្រឹតទេ សេចក្តីពិត មិនមានរូបអ្វីមួយដែល
វ៉ែងឬនឹងថ្កល់ឡើយ សុទ្ធសឹងតែកំរើក សុទ្ធសឹងវិបែប្រួល សុទ្ធសឹង
ផ្លាស់ប្តូរជានិច្ចរឿយៗ ។

ព្រះពុទ្ធសាសនា ជាសាសនាសម្មាទិដ្ឋិ សំដែងពីការយល់ឃើញ
ត្រូវ យល់ឃើញពិតតាមសភាពពិត ។ ប្រសេសយើងមានភ័ព្វបានជួប
ព្រះពុទ្ធសាសនា ទុកដូចជាយើងមានពេជ្រជារតនវត្ថុដ៏ខ្ពង់ខ្ពស់ ។ យើង
បានពេជ្រគឺពុទ្ធសាសនាហើយ តែយើងសំគាល់ថាជាត្បូងថ្ម យើងមិន
សូវខំប្រឹងប្រតិបត្តិតាម ដើម្បីឲ្យបានមគ្គផលសមតាមសេចក្តីត្រូវការ
យើងបែរទៅជាព្រងើយកន្តើយ ទុកព្រះពុទ្ធសាសនាគ្រាន់តែជាទំនៀម
ស្រុក ។ ពាំងនេះ មកពីបញ្ញាចក្ខុយើងមិនសុគ្រឹត ។ ព្រះពុទ្ធសាសនា
ប្រៀដូចថា បើចិត្តយើងជាសមាធិ មើលអ្វីតែងឃើញច្បាស់តាមយថាភូត
ដូចជាយើងមើលទៅកន្ងែកថ្ម ឃើញតែមានស្រកាក្តាំផ្លែកហែហែល

ចាត់ យើញដុំក្រែស ដុំថ្ម ខ្សាច ខ្មៅ មានពណ៌ចំត្រនៅជាតដី ប្រៀបដូច
អ្នកជាជ្រូបនិយមវិទ្យា ធ្វើនិទស្សន៍មើលមុខថ្មដូច្នោះឯង ។ យើង
ត្រូវបួលឆ្នាំទៅតាមលោកនិយម តែយើងត្រូវមានស្មារតីនឹកវលីកថា:
"អាត្មាអញបេញ្ចុតឆ្នាំចាស់ បួលកងឆ្នាំថ្មួយទៀតហើយ ដីវិតអាត្មា
អញកន្លងទៅបានប៉ុណ្ណោះឆ្នាំហើយ ថ្ងៃ ខែ ឆ្នាំដែលកន្លងទៅនេះ មិន
មែនកន្លងទៅឯកឯងទេ បានដញ្ជក់ស៊ីសាច់ឈាមហើយកន្លងទៅ បាន
ជាខ្លួនអាត្មាអញត្រូវគាំគែ ចាស់បន្តិចម្តងៗជាជរាប អត្តភាពដែល
តាំងនៅនេះ គ្រាន់តែជាគ្រឿងលួងជាមាយាឡូកលេង ឬជាដុំក្លែងមួយ
ប៉ុណ្ណោះ មិនមែនតាំងរហូតអស់កប្បទេ ខ្លួនអាត្មាអញប្រៀបដូចជាគោ
ដែលគេបំរុងនឹងសម្លាប់, ថ្ងៃមួយកន្លងទៅទុកដូចជាគោឈានដើងបួលទៅ
ជិតទីគេសម្លាប់បានមួយជំហាន ។ អាយុគឺជីវិតអាត្មាអញនេះតិចណាស់
មានស្មើនឹងខណៈចិត្តមួយ ភ្លឹមភ្លែត ៗ ដូចពន្លឺរំពិលអំពែកឬដូចផ្លេក
បន្ទោរឮដអាកាស បើខណៈចិត្តមួយកើតឡើង ជីវិតក៏កើតឡើង ខណៈ
ចិត្តរលត់ ជីវិតក៏រលត់ទៅស្មើគ្នា ជីវិតនេះ កើតរលត់ៗយ៉ាងនេះរៀងទៅ
ដូចព្រះគាសិតថា: "កាលខណៈចិត្តកន្លងផុតទៅហើយ សត្វឈ្មោះថាវស់
នៅរួចហើយ ឈ្មោះថាកំពុងវស់នៅក៏ទេ ឈ្មោះថានឹងវស់នៅក៏ទេ កាល
ខណៈចិត្តមិនទាន់មានមក សត្វឈ្មោះថានឹងវស់នៅ ឈ្មោះថាកំពុងវស់
នៅក៏ទេ ឈ្មោះថាវស់នៅរួចហើយក៏ទេ, កាលខណៈចិត្តកំពុងកើតឡើង

សត្វ ឈ្មោះថាកំពុងរស់នៅ ឈ្មោះថារស់នៅរួចហើយក៏ខ្លះ ឈ្មោះថា
នឹងរស់នៅក៏ខ្លះ" ។ មានគាថាមួយទៀតបញ្ជាក់ថា: "ជីវិតក្តី អត្ត-
ភាពក្តី សេចក្តីសុខទុក្ខទាំងអស់ក្តី ប្រព្រឹត្តទៅស្មើក្នុងខណៈចិត្តតែមួយ
ឯខណៈចិត្ត តែងប្រព្រឹត្តទៅរហ័សណាស់" ។ សេចក្តីយល់របស់យើង
ថា អាត្មាអញរស់នៅមានអាយុ ប៉ុណ្ណោះប៉ុណ្ណោះឆ្នាំនោះ ជាសេចក្តី
យល់តុហក ជាសេចក្តីយល់មាយា មិនមែនពិតទៅតាមសេចក្តីពិត មិន
មែនពិតប្រាកដទេ ។

ហេតុនេះ កថាវឿងបូលឆ្នាំ យើងត្រូវធ្វើសេចក្តីយល់ជាថ្មីវិញថា
ពាក្យពេចន៍ទាំងអស់ជាឈ្មោះនាមធម្មតា រូបធម្មតា ដូចជាឈ្មោះរបស់
ឈ្មោះមនុស្ស ឈ្មោះសត្វជាដើម សុទ្ធសឹងជាពាក្យសន្មត ជាគ្រឿង
សញ្ញាសម្រាប់ហៅនាមធម៌រូបធម៌នោះៗ ទៅតាមលោកនិយមប៉ុណ្ណោះទេ
ប្រាប់រូបធម៌ លោកពោលថា គ្រាន់តែជាជាតុ មិនមែនសត្វ មិនមែនជាជីវិត
ជាតាពសួន្យ, ប្រាប់ជានាមធម៌ គ្រាន់តែជាពាក្យសន្មតហៅទៅតាមសភាវ
ធម៌ ។ យើងមិនគួរកត់យកប្រយោជន៍ហួសហេតុដោយពាក្យថា បូលឆ្នាំ
ដែលជាពាក្យលោកសន្មតនេះពេកទេ ។ គួរពិចារណាឲ្យយល់ច្បាស់
សភាវធម៌ ធ្វើទុច្ចរិតដោយគ្រាជា ខំប្រកបគឺអត្ថតាពយើងគ្រប់គ្នាឲ្យរួប
ស្រួល ហើយបូលទៅកាន់សិវឋ្ឋានគឺអមតមហានិព្វាន ជាឋានសេដ
មានចេញប្រាប់បូលឆ្នាំនេះទៀត ។

# សេចក្តីសង្ខេប

នៅភូមិផ្ទះស្លឹកតូចមួយ ដែលមានសួនច្បារផ្កាដេរដាសន្ធឹងដើម
ឈើធំៗ ទ្រឈឹងទ្រលៃព័ន្ធជុំវិញ មកវត្ត អង្គុយសំកាំងនៅមុខតុជិត
មាត់បង្អួច ចោលភ្នែកក្រឡេកមើលទៅឆ្ងាយ ម៉ើលដើងមេឃនេះដូច
ភ្លើងនៃពេលអស្តង្គត ។

បុរសនោះអាយុប្រហែល ៣៥ឆ្នាំ ។ ថ្ងាសខូលាយជ្រញ៉ាដោយ
ផ្នត់ខ្ទង់ជ្រៅ ដែលជាស្នាមគំនូសនៃសេចក្តីគិតគូរច្រើនទំនឹងសេចក្តីព្រួយ
បារម្ភ ។ រស្មីនៃសេចក្តីឆ្លៀវឆ្លាតរាងរៃព្រាយបេញពីភ្នែកមូលស្រួច ។
ចិញ្ចើមទាំងគូ ក្រញ៉ូវដោយរោមវែង ។ ត្របាញ់ចូលគ្នាខ្លីងទ្រទុង
ត្រង់ច្រមុះ ។ មាត់រង្វង់ធំញញឹមស្នូតនឹងទឹកមុខស្រងូតស្រងាត់សម្តែង
នូវសេចក្តីអស់សង្ឃឹម ។ ក្រដាសពេញដោយអក្សរល្អិតស្មៀនយ
ពាយតតសណ្តាប់នៅលើតុ ។

រស្មីគ្រហមចំរុះលឿងជាន់ក្រាយបង្អួចនៃព្រះអាទិត្យ រលត់រលាយ
សន្សឹមៗទៅ ។ វត្តិការលាតស្រៀវឡើងចូលគ្រប់ពិភពលោកជា
លំដាប់ៗ ។ ភ្នែកដែលយឺតយូរជាងគេ ច្រឹងទទេះស្ងាបយ៉ាងធាប់ច្រញាប់
សំដៅទៅកាន់ទ្រនំដោយបន្ទឹងសំរែកគោកគាកៗ ។ លាពន្លឺថ្ងៃដោយ
សេចក្តីស្តាយ បក្សាបក្សីគាំងឡាយចូលពួនសំងំយ៉ាងព្រួយបារម្ភស្រងេះ
ស្រងោចកងសម្បុក ។ សម្លេងស្រមៃស្ងាត់ឃាត់ឮមាត់ទាំងអស់ ។

យប់ចូលដល់ហើយ ។ ឯសើមេឃ តាវាកវេំលុះសេចក្តីងងឹតបន្ទិច
ពន្លឺព្រិចៗមួយម្ដងៗ ។

ពេលយប់ពុំមែនជាសេចក្តីស្ងាត់ សេចក្តីអន្ធការ សេចក្តីអស់
សង្ឃឹមប្លុ? មកវិញ ដែលសំដែងកិរិយានៅដោយក្តីងប់ារម្ភផង ។ អង្គុយ
ជញ្ជឹងគិតម្នាក់ឯងដូច្នោះ អស់កំឡាងចិត្តព្យាយាមធ្វើកិច្ចការរបស់ខ្លួន
តទៅទៀត ទឹកចង្កើតចិត្តអាណិតបពន្ធពេកពន់ បពន្ធដែលស្ងួលក់
មាសពេជ្រទំញុតូបបែកបរបរចិញ្ចឹមជីវិត ដោយឥតគិតនឿយព្រួយ
លំបាកសោះ ឲ្យតែប្តីមានពេលទំនេរបង្ហើយកិច្ចការ ។

មកវិញ ទឹកដល់កិច្ចដែលស្វាមីគប្បីសង្គ្រោះកិរិយា ក៏ដកដង្ហើមធំ ។
ពេលនោះបន្ទប់ក្តីស្ងាត់ឈឹង នាងកន្យា កាន់ចង្កើតចូលមក ។

ពន្លឺចង្កើតចោលរង្គឹតរស្មី នៃសេចក្តីភក្តីព្ធដ៏ក្សាលនាងកន្យា
ទំរង់មុខនាងពុំបានជាសោកីទេ តែមានសំរស់ទន់ភ្ញន់ផ្សាយចេញពីមុខ
នាងមក ។ យកចង្កើតដាក់លើតុ នាងសាកសួរប្តីអំពីកិច្ចការក្នុងថ្ងៃ
នោះ ។ មកវិញ តបដោយល្ងើយថា :

— ប្អូន, បងមិនគួរបណ្តាយឲ្យឯងនឿយទាំងមានផ្ទៃពោះដល់
ម្ល៉េះទេ ។ ថ្ងៃស្អែកនេះ បងនឹងនៅស្ងៀរកការធ្វើចិញ្ចឹមឯងម្ដង ។

— ដូចម្ដេចក៏បងមានប្រសាសន៍ដូច្នោះ?

— កិច្ចការរបស់បងមិនបំពើនសោះ

– បង, បងនឹកស្រណោះដល់ខ្ញុំនខ្ញុំ ខ្ញុំមានសេចក្តីត្រេកអរណាស់ ។ ខ្ញុំស៊ូបំរើបងទាំងម្ល៉ះ គឺបង់ឲ្យបងបំពេញការណ៍យកចិត្តបំពោះអក្សរសាស្ត្រខ្មែរឲ្យពេញបន្ទុក ។ ស្រមិនបើបងទំលាក់ធុរៈចោលកណ្តាលដំណើរដូច្នេះ តំដូចជាបងដើរសេធពលើកម្មវិធីរបស់ប្អូនចោលស្មុះ ។ យើងគួរតែសន្សំរក្សាសេចក្តីសង្ឃឹមទុកជានិច្ចគ្រប់ពេល ទើបធ្វើកិច្ចការអ្វីៗបានសំរេចដូចបំណង ឯដំណឹតសោតក៏ងឹងគួរដល់ការរស់នៅគ្រប់វេលា ។

មកវន្ត ភ្ញាក់ខ្លួនដោយសំដីបពន្ធ ស្រស់មុខពពាយ ។

ចាប់ពីថ្ងៃនោះមក មកវន្ត ចាប់ធ្វើការដោយបីតរីករាយលែងរាយមាយនឹកគិតអាណិតបពន្ធទៀត ។ តែម្ល៉ងនេះ ពុំបានលោតទៅតាមកំលាំងគំនិតដែលផុសផុលក្នុងចិត្តនោះទេ បានរិះរៃតាំងរបៀបធ្វើការតាមលំនាំអ្នកស្ថាបនាទាំងឡាយ គឺពិចារណាជជីកកកាយទំលុះទំលាយគំនិតនោះដោយហ្មត់ចត់ រៀបចេញជាបទជាសង្ខ្លាត់ចាត់ជាផែនការមានរបៀបរៀបរយល្អ ទើបចុះដៃសរសេរវចនាពាក្យពេចន៍រំលេចគ្រាប់ កាច់រាងឲ្យចេញស្រស់បញ្ចង់ នឹងឲ្យញាប់ញ័ររំភើបដោយជំរាបសួរវើត ។

លុះសំរេចកិច្ចការចប់បរិបូណ៌ហើយ មកវន្ត ឧបស្ថាដៃរបស់ខ្លួនដើរស្វែងរកអ្នកបោះសៀវភៅ បានចួបប្រទះនឹងអ្នកយល់ការម្នាក់ ក៏ពន្យល់វត្ថុបំណងរបស់ខ្លួនប្រាប់អ្នកនោះដោយសព្វគ្រប់ ។ អ្នកផ្សាយសៀវភៅបូលចិត្តស្តាប់បាន ហើយពិនិត្យទៅឃើញការពារបស់មកវន្តវិសេស

មែន ព្រមទទួលផ្សាយកិច្ចការនោះ សន្យាចែករង្វាន់ឲ្យអ្នកនិពន្ធម្នាក់ក្នុង
រយៈលើ ប្រាក់ចំណេញ ។

តពីនោះមកមិនយូរប៉ុន្មាន កន្យា ដល់ពេលជិតសំរាលកូន ត្រូវ
ឈប់សំរាកខ្លួន ប្រាន់តួបសន្យំ ប្រាក់ទុកបំរុងពេលអាសន្ន ។ ដល់
ពេលឈឺពោះ នាងភ័យតក់ស្លុតជាទីបំផុត រហូតដល់អត់ពុំបានលាន់
មាត់ថា មកន្ត អាស្អរ ប្រពន្ធណាស់ ស្ទុះទៅជួយរិតរួតនួតឲ្យសព្វអន្ទឹ
ទោះខំធ្វើយ៉ាងណាៗ ក៏ជាការឥតអំពើ ទ័លចំណេះអង្គុយសំរក់ទឹកភ្នែក ។
កន្យា យើញប្តីកើតទុក្ខ ប្រឹងញញឹមទៅវិញ ។

កូនប្រុសចេញមកទទួលពន្ធុ ព្រះអាទិត្យពេលរសៀលជ្រៃ ។ និមិត្ត
តែយាយធ្លាប់បំពេញកិច្ចចំពោះទារកប្រុសភ្លាម ឪពុកម្តាយក្អាកក្អាយដណ្តើម
គ្នាបីបម្ចាក់ថ្នមកូន ដែលជាកម្មវត្ថុនៃសេចក្តីស្រឡាញ់ឥតខ្ចោះខ្ចាយរបស់
ខ្លួន ។ ទឹងកេសន្យានភាពឯណាឲ្យវិសេសសៃក្រលែងជាងការប្រុងប្រយ័ត្ន
យ៉ាងដិតស្និទ្ធនៃជនទាំងបីរូបនោះ! មាតាដែលនៅឈឺចាប់ដេកសន្ធឹងស្តឹង
ស្តូកនៅឡើយ ខំលូកដៃទៅបបោសអង្អែលបុត្រដោយសេចក្តីមេត្រី
ស្នេហា ចំណែកបិតាប្រាន់ប្រអ្នកទាំងពីរ ។

ផ្ទះឆ្អែបតែសូន្យស្ងាត់ បែរជាគឹកកងរំពងពីព្រលឹមទល់ព្រលប់
ដោយសូរសព្ទ សើចសប្បាយ ពាក្យទំយើនឹងចំរៀងបំពេ ។

ព្រឹកមួយ ប្តីប្រពន្ធគ្រោកចាកដំណេកពីព្រលឹម ដោយគ្មានអ្វីទំញុះអាហារសំរាប់ថ្ងៃនោះសោះ តែចិត្តអ្នកទាំងពីរនៅញុះញឹមសង្ឃឹមមាំដដែល ។ មកវិញ រៀបរៃសំអាតផ្ទះ និងរៀបចំគ្រឿងសក្ការបូជាប្លែកពីពេលមុនៗ រួចបាននាំប្រពន្ធកូនទៅអង្គុយលេងនៅមុខផ្ទះចាំទទួលទេវតាថ្មី ។

ព្រះអាទិត្យនៃឆ្នាំថ្មីរះឡើងហើយ ផ្សាយរស្មីនឹងសេចក្តីសុខក្សេមក្សាន្តជ្រួតជ្រាបពេញខ្លួនអ្នកទាំងពីរ ។ និកដល់ថ្ងៃជាមង្គលនោះ ខ្លួនគ្មានអ្វីនឹងទទួលទេព្រោតាមទំនៀម មានការធ្វើបុណ្យជាក់ពានជាដើម មកវិញនឹងកន្សោ ហួសនឹកដល់អ្នកកំសត់ជាងខ្លួន តើតសេចក្តីអាណិតដល់អ្នកទាំងនោះ ផ្សាយមេត្តាស្រោចស្រង់ទោរទន់ទៅវិញ ។ មានតែចិត្តទន់ភ្លន់ប៉ុណ្ណោះ សំរាប់ទទួលទេព្រោថ្មី ដើម្បីជាក់ថាសិរីសួស្តីនឹងចូលមកស្ថិតក្នុងផ្ទះរបស់ខ្លួនដោយពិត ។

ទេព្រោថ្មីចូលមកស្ថិតក្នុងភូមិនោះមែន ក្នុងរូបអ្នកផ្សាយសៀវភៅដែលចូលមកវាគអ្នកម្ចាស់ផ្ទះ ដោយកាន់សៀវភៅច្រាំនៅដៃនឹងផ្កាមួយដុំ ។ អ្នកនោះហុចផ្កាឲ្យកន្សោ សៀវភៅឲ្យមកវិញ លើកកូនខ្ចីបីពរជ័យព្រលឹងហើយថ្លែងសព្ទសាធុការពរតាមទំនៀម ព្រមទាំងប្រគល់រង្វាន់សៀវភៅឲ្យផង ។ មកវិញ ធ្វើយតបទៅវិញដោយអាក់ខាក់ សម្តែងសេចក្តីត្រេកអរដោយស្មោះសរ និងសេចក្តីស្តាយដែលពុំអាចនឹងគំនាប់ក្បៀវតាមការគួរ

កង់ពេលនោះ ។ ក្មេវបញ្ជាក់ថា គាត្យរបស់គាត់បានទទួលទឹក
សេចក្តីសរសើរពីសំណាក់អ្នកអានគ្រប់ៗ គ្នា ហើយបានសុំសិទ្ធិដាច់
ខាតនឹងផ្សាយកិច្ចការរបស់មកវន្តតទៅ ។

លុះក្មេវណោះចេញទៅហើយ មកវន្ត ងាកទៅនិយាយនឹងព្រះអាទិត្យដែលញាំងបកក្រាបក្បែរ
គ្រែកអរសាទរក្នុងលោក ។ ពរទាំងបួនប្រការ ដែលគេតែងឲ្យគ្នាក្នុង
វេលាចូលឆ្នាំថ្មីនោះ យើងបានឲ្យដល់ខ្លួនយើងដោយសេចក្តីព្យាយាម
របស់យើងហើយ" ។

ពេលនោះ ព្រះអាទិត្យដែលចាំងចាត់ក្រោយដើមស្វាយធំនៅចំពី
មុខផ្ទះ លេចអណ្តែតកន្លងទៅ ផ្សាយរស្មីពាងពាតលើអ្នកទាំង
បីរូប ដែលកំពុងប្រកៀកគ្នាប្រកិតយ៉ាងស្និទ្ធ ។ កូនតូចនៅតណ្តាល
ដុំពុកម្តាយ ព្រឹលក្អែកសែកសប្បាយតាមភាសាគាត ។ កន្សាទឹង
មកវន្ត យើញកូនកន្ត្រោលដូច្នោះ នាំគ្នាសើច សើចយ៉ាងស្រួលចិត្ត
លាន់ពីរោះនាពេលព្រឹកត្រាលនោះ ។

# ឧបត្ថំឆ្នាំឬ

ពន្ធីប្រកាតវាតមេឃា ជាលង្អុះបូជាគ្រហមខ្ញុំ
ប្រកាសអរុណមុនថ្ងៃថ្មី បណ្តេញភតីដណ្តើមហាន ។
នៅឯឆុយដោកលោកមិនស្រស់ សម្អុយតាំងអស់នៅឆ្ងន់ច្រណា
សំយាកសំយុងតតដឹងដាន ទ្រូតាំងភូមិហានស្ងាត់មហិមា ។
ឆ្ងាយអស់រស្មីទៅមួយម្ខង មានរដាវកងច្រាបទិព
ផ្ទៃលង្កែព្រសាទបន្តគា សត្វគោរដាក្អាយមាយ ។
សែងព្រះអាទិត្យរិតចាស់ឡើង ផ្ទៃមេឃចំប៉ើងព្រោតព្រោងព្រាយ
បក្សីសំអាតរូបទង់ទាយ តែកអរួសរាយឮសំឆ្ងើយឆ្ងង ។
ឃ្លាំបក់ត្រសៀកលោមលោតា ប្រលោមស្នូហាឮញ៉ែងញ៉ង
ដែលពាទន្ទេងលេងលើទង ពេយរាយលំអងសុគន្ធសាយ ។
ស្រមោលឆ្នាំចាស់ត្រូវផ្ទាស់ទៅ យឺតដំអក់នៅពោលសោកស្តាយ
បែកពីធម្មជាតិយូតទៅឆ្ងាយ រន្ធត់អង្កាយណាយចំប្រៃ ។
ទៅហើយគេចកែប្រែលំគេញ ទ្រូតម្ងោទោម្ញេទន្ទេញសព្ទ
សំរក់ទឹកភ្នែកភ័ន្តឡឹនឡប់ ហៀហូរសស្រប់ចប់ចុងស្មៅ ។
ស្រណោះឆ្ងារទឹកដែពព្រឹក្សា ស្រណោះបុប្ផាផ្កាស្រងៅ
ស្រណោះស្រណោកសាំសោកស្រៅ ស្រណោះចាប់រៅលោមលាកលា ។
តែដល់ពេលហើយកន្ទើយម្តេច ចាំចាប់វែះគេចលេចអង្កា

សែងព្រះទិនករលេបជន្មា ឲ្យព្រាត់ប្រាសគ្នា អនិច្ចា ។
ឆ្នាំឆ្លូវទៅបាត់ស្ងាត់ស្រឡះ ឆ្នាំខាលក៏រះតាមស្រួល
ល្អូខដំរង់កក្លែសមសក្តា បែកបរេចស្ពាសដាំក្តាត់ ។
ហើរប្រទក្សិណដោយក្លៀវក្លា សព្វសត្វសកុណាឆ្ងាធ្លៀលឆ្ងាត់
ធម្មជាតិព្រេចព្រឹកថ្ងៃប្រមាត់ មេឃខៀវស្រងាត់គួរសប្បាយ ។
បទុមគ្រប់ពណ៌ក្នុងស្រះស្រង់ រីកស្រស់បញ្ចង់ធើតពោមផាយ
ផ្សែងដូចស្មាបសត្វហើរឆ្ងាត់ឆ្ងាយ ពីផ្ទះទាំងឡាយសាយវាតា ។
ឮតែសូរសព្ទស្រែកល្ហែងល្ហើយ ឆ្នាំថ្លីកើតហើយកើតហើយណា
សេចក្តីសង្ឃឹមសោមនស្សា ផុសផុលជ្រះថ្លាសព្វទិសទី ។
រុក្ខជាតិលាស់ស្លឹកលេចពន្លក ចេញផ្កាថ្មីមកល្អសោភី
ប្រែពោមលោមពណ៌ជាសប្បិយពី ជីវិតន្ទួយស្រស់ចលនា ។
អាសូរឆ្នាំឆ្លូវដែលទៅបាត់ វិនាសសូន្យស្ងាត់គ្រប់ចំពូ
កណ្តាចកណ្តែងឯងឯកា តតមាននរណាទឹកដើមដល់ ។
គេនាំគ្នាអួតព្រេតពោលស្តី តែពីឆ្នាំថ្លីទាំងសកល
ផ្ងាស់ចិត្តគំនិតប្លែរយោបល់ ទឹងវែសូរកផលតាមលំអាន ។
ដរយោឆ្នាំខាលត្រកាលល្បី សូមសុខសួស្តីដល់សង្ឃាន្ត
ស្តុកស្តម្ភរុងរឿងពេចន៍សុខក្សេមក្សាន្ត ដល់អវសានសំពន្ធអើយ ។

# ចំរៀងចូលឆ្នាំ

ចុល – ថ្ងៃនេះជាថ្ងៃចូលឆ្នាំថ្មី យើងទាំងប្រុសស្រីជួបគ្នាម្តង
គួរបបួលគ្នាសាកសួរសង នួនល្អងចូលចិត្តរឿងអ្វីពៅ ។
តើឆ្លៀតត្រង់ណាឲ្យបងធ្វើយ កុំអៀនអន់ឡើយដេញដោលទៅ
ទោះជាប្រស្នាពាក់ប្តូរជ្រែ តូចតន់កុំនៅស្ងៀមដល់ណា ។

ស្រី – សាធុការនេះពេញល្អហើយ អ្នកប្រុសគ្រាណាត្រៃយមានចាស់ជ្រួ
បងប្រែងស្តាប់ចុះសំពួរពាក្យ កល្យាណ៍សួរអ្នកមិនឲ្យហ្មង ។
អ្វីជាពន្លឺបំភ្លឺជាតិ តបះព្រោងពាក្យកែកន្ទុង
នាំជាតិឲ្យខ្ពស់សព្វកាលផង សូមអ្នកប្រុសបងធ្វើយធាប់វៃ ។

ចុល – ពន្លឺព្រះច័ន្ទភ្លឺតែយប់ ព្រះសុរ្យភ្លឺគប់តែពេលថ្ងៃ
មិនភ្លឺសព្វពេលទេស្រីថ្ងៃ តែវាកុំសង្ស័យណាមាសស្ងួន ។
ត្រង់នេះអ្នកចាស់ជ្រួលោកចែងថា ពន្លឺថ្ងៃថ្លាស័ក្តិសមស្ងួន
គឺអក្សរសាស្ត្រមាក្បួន គប់ជាតិខំស្ងួនរក្សាទុក ។
អក្សរជាតួពន្លឺជាតិ ពណ្ណភាយពុំឃ្លាតសម្រាប់ស្រុក
ហេតុនោះកូនប្រុសកុំសំកុក គួរសុខចិត្តខំរៀនអក្សរ ។

ស្រី – ហៅសមកន្ទុងពាក្យបងថា ប្រទេសនានាគេតែកអរ
អប់រំបន្ទុំផ្នែកអក្សរ ពន្លឺបវរធ្ងុះជាតិគេ ។
តែត្រង់បបួលតែពួកប្រុស នេះពេញហៅខុសមិនត្រូវទេ
ត្រង់ស្រីជួបម្តេចក៏វេះវៃ គួរឲ្យស្រីរៀនគប់គ្នា ។

ប៊ុស – មុខងារស្រីៗ ផ្ទះសម្បែង ជាំស្ងោរចាត់ចែងស្ងួនបុត្រភ្លោះ
ដោះចាស់ជួសជុលមើលមនុស្សម្នា ឲ្យបានសុខជា, ជាប្រក្រតី ។
បេះទទួលក្មេងដោយយកត់ទាក់ ស្មោះស្ម័គ្រដល់ញាតិទាំងប៊ុសស្រី
ឲ្យបេះអក្សរបានការអ្វី ចង់ដឹងស្ងួរប្តី ។ បេះស្រាប់ ។

សៀ – បងយល់ដូច្នោះពុំត្រូវទេ ស្រីប្រទេសគេចេះចំណាប់
ព្យាយាមរៀនសូត្រអស់ក្បួនច្បាប់ ទើបមានសណ្តាប់ធ្នើតប្រពៃ ។
ស្រុកយើងពុំដើមសម្បើមដែរ ពពួកស្រីខ្មែរស្អាត់ឆងវៃ
ខាងអក្សរសាស្ត្រប៉ុនលេកលៃ កែវខែឆ្នៃជាតិឲ្យក្តីថ្លា ។
ស្រីជាមាតាចិញ្ចឹមបុត្រ ជាគ្រូផ្តៃខាងរបងា
អប់រំបន្ទុំកែវកាស្តា នៃបុត្រធីតាឲ្យបវរ ។
បើស្រីល្ងីតល្ងង់ទឹងដឹងអ្វី ឯប្តីវល់តែត្រាច់បរ
ដូច្នេះស្រីគួររៀនអក្សរ អបអរជួយធ្យូរបង្រៀនកូន ។

## ប៊ុស - ស្រីប្រៀងព្រមគ្នា

អក្សរពន្ធប៉ក្តីជាតិ អក្សរយ៉ឹងយ៉ាតជាតិអាប់អួន
ចោះបង់អក្សរដូចសណ្តូន ចានជាតិឲ្យស្ងួទ្យាក់ចាតាល ។
ហេតុនេះជាតិយើងទាំងប៊ុសស្រី គប្បីខ្វីយ៉ាតស្ទុះត្រអាល
សិក្សាអក្សរឲ្យទាន់កាល សួយជាតិវិសាលវិសេសអីយ ។

ហេង · យ៉ាន់

៣១ - សូម្បីសក្កៈទេវរាជ បើមិនបានញ្ញែកចូលទ្វិយសស្សត្តិឲ្យគេ
ឃើញច្បាស់ទេ ក៏តែងបានការមើលងាយពីមហាជន បុគ្គលហ៊ានដើរ
កន្ទុងទុសដែលមានភ្លើងនៅខាងក្នុង តែកាលណាភ្លើងនេះហើយ បុគ្គល
មិនហ៊ានកន្ទុងឡើយ" ។

ភរដក: ឆ្លើយថា: "យើងតាំងពីនាក់មិនជាថ្មធានេ បើដូច្នោះ
យើងតាំងពីនាក់ទៅវិលក្នុងការណ៍នោះធ្វើអ្វី? ព្រោះថា:-

៣២ - មន្ត្រីណា ចរចាជាមួយព្រះរាជា ហើយមិនហ៊ានទូល
ស្តួរ មន្ត្រីនោះជាមនុស្សល្ងង់ខ្លៅ មិនមែនតែប៉ុណ្ណោះទេ មន្ត្រីនោះតែង
បាននូវការមិនរាប់រក ព្រមទាំងការមើលងាយពីព្រះរាជាថែមទៀតផង ។

៣៣ - កន្លែងណា បុគ្គលហាមាត់និយាយទៅហើយបាន
ផលឋិតថេរយូរ ដូចជាពាណិជាប់ឮដំណឹងដូច្នោះ កន្លែងនោះ
បុគ្គលគប្បីហាមាត់និយាយចុះ ។

ទមនក: ឆ្លើយកាត់ឡើងថា: "សំឡាញ់! សំឡាញ់ឯងកុំនិយាយ
យ៉ាងនេះ" ។

៣៤ – ថាបើគេសេពគប់ព្រះរាជា អ្នកមិនមែនប្រធាន អាចទៅជាប្រធានបាន, ថាបើគេវៀរបង់មិនសេពគប់ព្រះរាជាហើយ សូម្បីប្រធានក៏ឋិតនៅធ្លាក់ខ្លួនទៅជាមិនមែនប្រធានវិញ ។

៣៥ – ព្រះន្ទបតីតែងរាប់រកតែមនុស្សណា ដែលនៅជិតផ្លូវព្រះអង្គ មិនថាអ្នកនោះជាមនុស្សល្ងង់ខ្លៅ មានតែកូលចោកទាប ឬពុំនោះមានទ្រព្យមិនបានទូន្មាននេះ តាមធម្មតាព្រះរាជាក្តី ស្ត្រីតាពក្តី លតាជាតិក្តី តែងទាក់ទងព័ទ្ធព័ន្ធតែអ្នកណាឬដើមឈើណាដែលនៅជិត ។

៣៦ – សេវកាមាត្យណា ពិចារណាយើញច្បាស់នូវចំណុចដែលនាំឲ្យគ្រោធ ឬនាំឲ្យរីករាយព្រះទ័យ សេវកាមាត្យនោះ អាចខ្សឹងថ្លាក់បន្ទិចម្តងៗ ទៅដល់ជិតព្រះរាជាដែលយោរយៅខ្លាំងនៃក្រចាន ។

៣៧ (១) មនុស្សមានវិជ្ជា មនុស្សក្រាបថ្ងាធំ មនុស្សមានសិល្បសាស្ត្រ មនុស្សមានសេចក្តីក្លៀវក្លាហាន និងមនុស្សចេះប្រព្រឹត្តខ្លួនជាសេវកាមាត្យ ទាំងអស់នេះ មិនមានទំពឹងគ្រៅពីព្រះរាជាទេ ។

៣៨ – នរជនណា សូម្បីមានឧស្សាហ៍ធំខ្លាំងនៃក្រចៃដែលកើតពីគុណសម្បត្តិមានជាតិជាដើម តែមិនបួលទៅជិតពឹងព្រះរាជា នរជននោះមានតែការដើរសូមទានគេនឹងទ្វារគម្ចាសំណាងរហូតមរណភាព ។

---

១ គាថាលេខ ៣៧ - ៣៨ - ៣៩ ទាំង ៣ នេះ ប្រហែលជាប្រើក្នុងសម័យរាជនិយម ឬកំពង់ស៍ពូនេះសំដៅយកសេចក្តីថាការរាជការទាំងមូល ដូចពាក្យថាឯករាជ្យដូច្នេះ ? ។

៣៩ – មនុស្សណាតែងពោលថា "ព្រះរាជាព្រះទ័យអាក្រក់ណាស់ ពិបាកនឹងធ្វើឲ្យទ្រង់ជ្រាបជ្រាណាស់" នេះជាពាក្យពោលសំដែងសេចក្តីប្រមាទ សេចក្តីឧឡើមអួស ទឹងសេចក្តីល្ងង់របស់ខ្លួនរបស់មនុស្សនោះទេ ។

៤០ – កាលបើយើញគេខ្លួនាន ពស់, ខ្លា, ដំរី, សីហៈ ឲ្យនៅក្នុងំណាចខ្លួនបានដោយឧបាយណាមួយហើយ សព្វបើព្រះរាជា ដូចម្តេចក៏អ្នកជ្រាជ្ញដែលមិនប្រមាទ មិនអាចធ្វើឲ្យនៅក្នុងំណាចខ្លួនបាន ?

៤១ – អ្នកជ្រាជ្ញ អាស្រ័យនឹងព្រះរាជា បាននឿងដល់ហានៈដ៏ខ្លាំងខ្លាស់ ដូចខ្លឹមចន្ទន៍មិនដុះក្រៅពីភ្នំមលយៈ[1] ឡើយ ។

៤២ – កាលបើព្រះរាជាសព្វព្រះទ័យហើយ គេនឹងបានខ្វល់ស្តុស ស្តេះជាទីពេញចិត្តនឹងជិតក្បែរក្បា គ្រប់កាលគ្រាំងពួន ។

ករជកៈសួរថា : "បើដូច្នេះតើ សំឡាញ់ឯងចង់ធ្វើដូចម្តេច ?" ។

មនកៈឆ្លើយថា : "នែសំឡាញ់! ថ្ងៃនេះ បិដ្ឋលកៈម្ចាស់យើង កំពុងតក់ស្តុតរន្ធត់ ព្រមមួយអន្ទើដោយបរិវារ យើងបួលទៅម្ចាស់យើងសួរហេតុនៃសេចក្តីភ័យខ្លាចនោះឲ្យដឹង ហើយយើងនឹងណែនាំឲ្យទ្រង់ធ្វើសន្តិភាពឬធ្វើសង្គ្រាមឬភ័យគ្រាទៅមុខ បើមិនដូច្នោះ តាំងព័ត្បួងខ្លួនចាំ ពុំនោះរកសម្ពន្ធមិត្តជួយការពារ ពុំនោះសោត កេណ្ឌរេហ៍ពលបន្ថែម

---

• នៅជួរភ្នំភាគឦសានប្រទេសឥណ្ឌា មានដើមខ្លឹមចន្ទន៍ល្អ មានល្បីឈ្មោះជាគេ ។

ខ្មៀត" ។ ភរដក:ស្ទុះដោយឈឺចុលស់ថា: "សំឡាញ់! ហេតុដូចម្តេច តើ
បានជាឯងដឹងថាម្ចាស់យើងភ័យខ្លាច?" ។ ទមនក:ឆ្លើយថ្លែងថា:
"ម្តេចក៏គេមិនគប្បីដឹងបានវឿងនេះ? ។ ព្រោះថា:—

៤៣— ពាក្យពេចន៍ ដែលបុគ្គលពោលចេញហើយ សូម្បី
បសុសត្វក៏ចាប់យកសេចក្តីបាន, សេះនឹងដំរី ដែលគេហ្វឹកហ្វឺនហើយ
តាលបើជននិយាយ នាំជនទៅបាន; ជនជាបណ្ឌិតវាងវៃដឹងគាន់ សូម្បី
គេមិនគាន់ហាមាត់និយាយ ព្រោះថាថ្ងៃមានផលប្រសើរ គឺការដឹង
នូវទឹកចិត្តនៃជនដទៃ ដែលមានតំរិយាចេញមកខាងក្រៅ ។

៤៤— បុគ្គលអាចកត់សំគាល់បាន នូវចិត្តបុគ្គលដទៃដែលឋិតនៅ
ខាងក្នុងដោយអាការខាងក្រៅ គឺដោយចរិយា ដោយគតិ ដោយតំរិយា
ដោយទឹកសំដី និងដោយវិការនៃកែកនឹងមុខមាត់" ។

ដំណើរនេះ ខ្ញុំនឹងបួលទៅឲ្យដល់ម្ចាស់យើងដែលកំពុងជ្រួល
ច្របល់ដោយភ័យខ្លាចនេះ ហើយធ្វើកុំឲ្យខ្ជិលកិតភ័យឲ្យមានសេចក្តីក្លា
ហានដោយអំណាចប្រាជ្ញាខ្ញុំ ឲ្យខ្ជាប់តាំងនៅក្នុងអំណាចខ្ញុំស្រេចសិន
សិមសំរួលការ ដើរទៅតាមផ្លូវឲ្យបានជាមន្ត្រី ។ ភរដក:ពោលថា: "នែ
សំឡាញ់! ឯងមិនបេះបួចប់ធ្វើជាសេវកាមាត្យ, បើដូច្នោះតើ ឯងនឹងឲ្យ
ម្ចាស់ល្ងុះក្នុងអំណាចខ្លួនដូចម្តេចបាន?" ។ ទមនក:ឆ្លើយថា: "ដូចម្តេច

មន្ទីរសិល្បៈ
ក្រសួង
លេខបញ្ជី



ក៏ឯងថាខ្ញុំមិនចេះច្បាប់ធ្វើជាសេវាគាមាត្យ? ។ អនុជីវិធម៌[1] គាំងអស់មហាឫស៊ីឈ្មោះរេវ៉ាម្យ៉ាបាននោលហើយ កងកាលវែលពួកបាណ្ឌវៈបូលទៅកងនគរវិកជ នេះយាបាយគាំងអស់នេះ ខ្ញុំបានជឹងអស់ហើយ មិនមែនប្អូនអ្វី? កាលនៅជាមួយបិតាខ្ញុំ ខ្ញុំបានស្តាប់លោកអ្នកចាជ្ញទឹងភ្លៀវគាន ក្សត្រនេះយាបាយ ខ្ញុំបានបុតចាំសុភាសិតល្អៗដែលស្តីពីច្បាប់សេវាគាមាត្យ ចូរឯងស្តាប់ទូវសុភាសិតគាំងឡាយនោះ ដូចតទៅនេះ : —

៤៥ — ជនក្លៀវក្លា ជនចេះដឹងវិជ្ជា និងជនចេះច្បាប់សេវាគាមាត្យ ជន ៣ ពួកនេះ ទើបគប្បីព្រះរាជាដែលមានផ្កាជាមាសបាន ។

៤៦ — ធ្វើប្រយោជន៍ទ្បូម្ចាស់ផែនដី កាន់ពាក្យម្ចាស់ផែនដីដោយវិសេស គាំងអស់នេះទើបឈ្មោះថាចេះការបំរើម្ចាស់ផែនដី អ្នកចាជ្ញអាស្រ័យពឹងម្ចាស់ផែនដីដោយផ្លូវនេះមិនមានទ្វារដ៏ទៃក្រៅពីនេះឡើយ ។

៤៧ — ព្រះរាជាណា មិនស្គាល់គុណនៃអ្នកចាំផ្ចាំណា អ្នកចាជ្ញនោះមិនគប្បីសេពគប់ព្រះរាជានោះឡើយ ព្រោះមិនបានផលពីការសេពគប់នោះទេ ដូចជាដីឥតដីជាតិសម្បីក្បាលស្តេចមិនបានផល ។

---

១ ច្បាប់ធ្វើជាមន្ត្រី ជាឧម៉ុងធ៌ មានរឿងមន្ត្រីជាដើម ។

៤៨ – ព្រះរាជាសូម្បីក្សត់ទ្រព្យ ក្សត់អំណាច តែប្រកបដោយគុណគួរសេពគប់ បុគ្គលគប្បីសេពគប់ប៉ុះ ព្រោះគេបានផលជារង្វាន់ពីការនៅបំរើ សូម្បីមួយជង្គង់មួយកាល ។

៤៩ – ត្រូវអង្វយនឹងថ្ពល់ដូចបង្កើល រឹងស្តួតស្ងួតក្រញ៉ង់ស្ងាប់ដោយសេចក្តីស្រេកឃ្លានឬអ្វី ? អ្នកប្រាជ្ញមិនស្វែងរកទ្រព្យចំញឹមជីវិតដែលប្រាសចាកការសម្រេចដោយខ្លួនឯងទេឬ ។

៥០ – សេវាមាត្យណាស្មុគស្មាញដែន ដែលកំណាញ់ហើយពោលពាក្យអ្នកក្រក់ សេវាមាត្យណាមិនស្គាល់បុគ្គលគួរសេពគប់នឹងមិនគួរសេពគប់ សេវាមាត្យនោះ ឬដូចម្តេចកមិនស្មុគខ្លួនឯងផង ? ។

៥១ – សេវាមាត្យពឹងពាក់អាស្រ័យព្រះរាជាណា, ប៉ើដល់កាលអត់ស្រេកឃ្លាន ទ្រង់មិនប្រទានវត្ថុបំបាត់ស្រេកឃ្លាន បុគ្គលគប្បីលះបង់ព្រះរាជានោះចោលទៅ ដូចគេលះបង់ចោលដើមឈើអកើ : (១) សូម្បីឈើនោះមានផ្លែផ្កាគ្រប់កាល ។

៥២ – បុគ្គលគប្បីប្រតិបត្តិបន្ទុបខ្នុរគារព ព្រះពជមាតា អគ្គមហេសី ព្រះពជកុមារ នាយកវដ្ឋមន្ត្រី បុរោហិត ទីឆ្វារបាល ឲ្យដូចគោរពព្រះរាជា ។

---

១ ឈ្មោះដើមឈើ ។

៥៣ – នរជនណាប្រាជ្ញ ដឹងកិច្ចការដែលគួរធ្វើ. កាលបើព្រះ
ពុទ្ធាត្រាស់សួរ ធ្វើយទានក្លាមថា "ជីវ:!" ដូច្នេះ ហើយហ៊ានធ្វើការ
មិនញាប់ញ័ត នរជននោះធ្លាជាជំនិតម្ចាស់ផែនដីបាន ។

៥៤ – នរជនណាចេះរៀបចំខ្លួនឲ្យសមរម្យជាបុគ្គលគួរទទួលទាន
គឺទ្រព្យដែលកើតពីសេចក្តីដែះថ្លានៃម្ចាស់ផែនដី មានកាយប្រដាប់ដោយ
វត្តមានគ្រឿងពស្ត្រាផារដើម នរជននោះគប្បីបានជាជំនិតម្ចាស់ផែនដី ។
ទុ

៥៥ – នរជនណាមិនប្រព្រឹត្តធ្វើកិច្ចការអ្វីមួយដោយស្ងាត់ៗ ជា
មួយអ្នកបំរើនៃស្តេចព្រះរាជវាំង នឹងជាមួយព្រះអគ្គមហេសីនៃព្រះរាជា
នរជននោះគប្បីបានជាជំនិតម្ចាស់ផែនដី ។

៥៦ – នរជនណាគិតថា "អាត្មាអញគោរពគោតខ្វាចម្ចាស់ផែន
ដីអស់កាលជានិច្ច" ដូច្នេះហើយមិនប្រព្រឹត្តកន្ទួចព្រះរាជបញ្ជា សម្បី
តិចតួច នរជននោះគប្បីបានជាជំនិតម្ចាស់ផែនដី ។

៥៧ – នរជនណាចង់ពឹរដ៏ក្រៃលែងចំពោះសត្រូវនៃព្រះរាជា
នឹងធ្វើអំពើជាទីពេញចិត្តដល់ជនណាជាទីស្រឡាញ់ប្រាស្រ្តាណានៃ
ព្រះរាជាអស់កាលជានិច្ច នរជននោះគប្បីបានជាជំនិតម្ចាស់ផែនដី ។

៥៨ – នរជនណាមើលឃើញស្បែងទុកដូចជាយមទូត នូវស្រោ
ទុកដូចជាថ្នាំពុលដ៏ក្តៅក្រហាយ, នូវអគ្គមហេសីទុកដូចជាភ្លើងខ្លោចទីង
មោង នរជននោះគប្បីបានជាជំនិតម្ចាស់ផែនដី ។

៥៩ – (១) នរជនណា, ក្នុងកាលបម្រុងនឹងដើរទៅមុខ ក្នុងបុរីដើរ
វិហារតាមគ្រោយ, ក្នុងប្រាសាទបិតនៅមាត់ទ្វារព្រះរាជា សព្វៗ កាល
នរជននោះគប្បីបានជាជំនិតម្ចាស់ផែនដី ។

ភរដក: ស្តេចថា: "សំឡាញ់! លុះសំឡាញ់ឯងចូលទៅដល់ទី
នោះហើយ តើសំឡាញ់ឯងនិយាយដូចម្តេចខ្លះ? ឯងនិយាយឲ្យខ្ញុំស្តាប់
បន្តិចមើល! ។ ទមនក: ឆ្លើយប្រាប់ថា: –

៦០ – ក្នុងការចរចា ពាក្យមួយម៉ាត់ ធ្វើឲ្យកើតពាក្យមួយម៉ាត់
ទៀត ដូចជាពូជដែលប្រកបដោយគុណគឺក្លៀងល្អ នាំឲ្យបែកគុម្ពកើត
ជាពូជមួយថ្មីទៀត ។

(មានត)

---

១ បញ្ចូតន្ត្រៈ សេចក្តីប្រែជាភាសាបារាំងនៃណោតឡង់ស៊ូ មានគាថាលើសដូច្នេះ
ក - នរជនណា កាលបើអ្នកស់ផែនដីនិយាយ មិនឆ្លើយទាស់ មិនសើចខ្លាំងនៅទីដិត នរជន
នោះគប្បីបានជាជំនិតម្ចាស់ផែនដី ។ ខ – នរជនណាមិនខ្លាច នៅក្នុងសមរភូមិដូចនៅក្នុង
ផ្ទះខ្លួន, នៅក្នុងបរទេស ដូចនៅក្នុងប្រទេសខ្លួន, នរជននោះគប្បីបានជាជំនិតម្ចាស់ផែនដី ។
គ – នរជនណាមិនសមគមជាមួយអគ្គមហេសីព្រះរាជា, មិនរិះគន់, មិនរករឿងឈ្លោះ
នរជននេះគប្បីបានជាជំនិតម្ចាស់ផែនដី ។

BIBLIOTHÈQUE ROYALE